**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៤ សណន**

# សេចក្តីណែនាំ

# ស្តីពី

# តួនាទី ភារកិច្ច និងរបៀបរបបការងារ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន

រាជរដ្ឋាភិបាលបានរៀបចំក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដោយបានចាត់តាំងសមាជិក សមាជិកា រាជរដ្ឋាភិបាល និងមន្ត្រីរាជការតាមក្រសួង ស្ថាប័ន ជាសមាសភាពក្នុងក្រុមការងារនេះជាបន្តបន្ទាប់ សំដៅចូលរួម គាំទ្រ និងជំរុញការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់ រាជរដ្ឋាភិបាល ដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននានា និងចូលរួម បំផុសចលនាឱ្យមានការគាំទ្រ ការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានក្នុងការកសាងអភិវឌ្ឍប្រទេសជាតិឱ្យមាន ការរីកចម្រើនលើគ្រប់វិស័យ។

ផ្អែកលើសមិទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ ដំណាក់កាល នារយៈពេល២៥ឆ្នាំ កន្លងមក រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា បានសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រ បញ្ចកោណដំណាក់កាលទី១ និងបានសម្រេចបន្តចាត់តាំងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដើម្បីចូលរួមគាំទ្រ និងជំរុញការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ឱ្យបានសកម្មផុលផុសនៅតាមមូលដ្ឋាន ដើម្បីរួមគ្នាបន្តជំរុញ ការអភិវឌ្ឍប្រទេសជាតិឱ្យឈានចូលដំណាក់កាលថ្មី សំដៅឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការចុះបំពេញការងារនៅតាមមូលដ្ឋាននានា រាជរដ្ឋាភិបាលកំណត់អំពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានដូចខាងក្រោម៖

## I. តួនាទី ភារកិច្ច

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានមានតួនាទីតម្រង់ទិស គាំទ្រ និងជំរុញការលើកកម្ពស់សមត្ថភាព ស្ថាប័ននៅមូលដ្ឋាន ដើម្បីពង្រឹងការទទួលខុសត្រូវ និងភាពជាម្ចាស់របស់មូលដ្ឋានក្នុងការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល

៣. អនុប្រធាន និងសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននីមួយៗ ត្រូវបំពេញការងារតាមការចាត់តាំង ការប្រគល់ភារកិច្ច និងចូលរួមប្រជុំតាមការកំណត់របស់ប្រធានក្រុមការងារ។

៤. រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ននានា ត្រូវប្រគល់ភារកិច្ចជូនអង្គភាពជាក់លាក់ណាមួយ ឬអាចរៀបចំឱ្យមានមន្ត្រីបង្គោលក្នុងក្រសួង ស្ថាប័នសាមី ដើម្បីធ្វើជាសេនាធិការក្នុងការសម្របសម្រួលសកម្មភាពការងារចុះមូលដ្ឋាន និងបូកសរុបសកម្មភាពតំណាងក្រសួង ស្ថាប័នរបស់ខ្លួន ដែលបានចូលរួមក្នុងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងការដោះស្រាយឆ្លើយតបបញ្ហាប្រឈមនានានៅមូលដ្ឋានដែលពាក់ព័ន្ធសមត្ថកិច្ចក្រសួង ស្ថាប័នសាមី។

៥. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ត្រូវណែនាំដល់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំបង្កើតនូវលេខាធិការដ្ឋានសម្រាប់ធ្វើជាសេនាធិការដល់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដែលស្ថិតក្នុងសាលារាជធានី ខេត្ត និងសាលាក្រុង ស្រុក ខណ្ឌនីមួយៗ។

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំ សង្កាត់ ត្រូវសហការជាមួយរដ្ឋបាលឃុំ សង្កាត់សាមីធ្វើការចាត់តាំងមន្ត្រីបង្គោល ដើម្បីធ្វើជាសេនាធិការក្នុងសកម្មភាពការងារចុះមូលដ្ឋាន។

៦. ក្នុងការចុះបំពេញការងារនៅមូលដ្ឋាន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានពុំមានតួនាទី ឬសិទ្ធិសម្រេចកិច្ចការជំនួសក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ អង្គភាពជំនាញនានាឡើយ។ រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន អាជ្ញាធរ រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ អង្គភាពជំនាញនានា ត្រូវមានការទទួលខុសត្រូវលើកិច្ចការនានាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៧. ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននីមួយៗ ត្រូវចាត់ឱ្យអនុប្រធាន ឬសមាជិកក្រុមការងារដែលជាតំណាងក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ សហការសម្របសម្រួលក្នុងក្រសួង ស្ថាប័នសាមី ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ធ្វើការដោះស្រាយនូវបញ្ហាប្រឈម សំណើ សំណូមពរនានារបស់មូលដ្ឋាន និងត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងជំរុញសកម្មភាពដោះស្រាយបញ្ហាទាំងនោះ ដោយផ្អែកលើច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងវិធានការរបស់រាជរដ្ឋាភិបាល។ ករណីមិនអាចដោះស្រាយបាន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត អាចជួបពិភាក្សា ឬស្នើសុំឱ្យរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធដើម្បីចាត់វិធានការដោះស្រាយស្របតាមសមត្ថកិច្ចនៃក្រសួង ស្ថាប័ននីមួយៗ។ ករណីនៅតែមិនអាចដោះស្រាយបាន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ត្រូវបញ្ជូនមកលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដើម្បីធ្វើការបូកសរុបរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

៨. ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន អាចអញ្ជើញអាជ្ញាធរ រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ អង្គភាពពាក់ព័ន្ធនានានៅមូលដ្ឋាន ចូលរួមប្រជុំពិភាក្សាការងារតាមការចាំបាច់។

៩. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់ថ្នាក់ ត្រូវកំណត់របបប្រជុំ និងធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារយ៉ាងតិចមួយត្រីមាសម្តង ព្រមទាំងអាចកោះប្រជុំតាមការចាំបាច់ និងធ្វើរបាយការណ៍មកលេខាធិការដ្ឋាននៃក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដើម្បីបូកសរុបរាយការណ៍ជូនរាជរដ្ឋាភិបាល។

សំដៅធ្វើការអភិវឌ្ឍមូលដ្ឋាន ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការដោះស្រាយឆ្លើយតបសំណើ សំណូមពរ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ផ្អែកលើតួនាទីខាងលើនេះ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

១. លើកកម្ពស់ការផ្សារភ្ជាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដោយត្រូវសហការធ្វើការផ្សព្វផ្សាយដល់អាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ច និងប្រជាពលរដ្ឋនៅមូលដ្ឋានអំពីកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គោលនយោបាយ កម្មវិធីកំណែទម្រង់ និងវិធានការនានារបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ការគាំទ្រ ការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន។

២. ត្រូវសហការគាំទ្រដល់មូលដ្ឋានដែលក្រុមការងារចុះបំពេញការងារ ធ្វើការវាយតម្លៃអំពីសមត្ថភាពស្ថាប័ន ធនធានមនុស្ស និងសក្តានុពលនៃការអភិវឌ្ឍមូលដ្ឋាន សមិទ្ធផល បញ្ហាប្រឈមនានានៅក្នុងមូលដ្ឋានដើម្បីធ្វើការគាំទ្រដល់មូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល សំដៅជំរុញការអភិវឌ្ឍមូលដ្ឋាន ការផ្តល់សេវាសាធារណៈ និងការដោះស្រាយឆ្លើយតបបញ្ហាប្រឈមនានានៅមូលដ្ឋានឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

៣. ជំរុញ និងលើកកម្ពស់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ អង្គភាពជំនាញ អាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចនៅមូលដ្ឋានក្នុងការបំពេញការងារស្របតាមតួនាទីសមត្ថកិច្ចរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព។

៤. សហការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន និងចុះជួបប្រាស្រ័យដោយផ្ទាល់ជាមួយប្រជាពលរដ្ឋតាមមូលដ្ឋាន ដើម្បីស្វែងយល់ដោយផ្ទាល់នូវកង្វល់ បញ្ហាប្រឈម សំណើ និងសំណូមពរនានារបស់ប្រជាពលរដ្ឋដើម្បីសហការជំរុញដល់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច ធ្វើការដោះស្រាយឆ្លើយតបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

៥. សហការគាំទ្រ និងចូលរួមធ្វើអន្តរាគមន៍ដល់មូលដ្ឋាននៅពេលមានគ្រោះធម្មជាតិ ជំងឺឆ្លងរាតត្បាត ឬគ្រោះថ្នាក់ផ្សេងៗ ដើម្បីការពារ និងជួយសង្គ្រោះប្រជាពលរដ្ឋ។

៦. កៀរគរធនធាន មធ្យោបាយ សម្ភារពីប្រភពស្របច្បាប់នានា ដើម្បីចូលរួមគាំទ្រដល់ការអភិវឌ្ឍមូលដ្ឋាន ការកសាងសមិទ្ធផលសង្គម និងការដោះស្រាយឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

៧. បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់រាជរដ្ឋាភិបាល។

## II. របៀបរបបការងារ

១. ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ត្រូវមានការទទួលខុសត្រូវដឹកនាំណែនាំ និងត្រួតពិនិត្យសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់ថ្នាក់នៃរាជធានី ខេត្តនីមួយៗ។

២. ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ឃុំ សង្កាត់ ត្រូវមានការទទួលខុសត្រូវក្នុងការដឹកនាំ និងចាត់ចែងអនុវត្តការងារចុះមូលដ្ឋានក្នុងក្រុមការងាររបស់ខ្លួន ផ្អែកតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត។

## III. អំពីការចាត់តាំងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន

១. ផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ប្រធាន អនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្តនីមួយៗ ត្រូវពិគ្រោះពិភាក្សារៀបចំចាត់តាំងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ក្នុងរាជធានី ខេត្តសាមី ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្តនីមួយៗឱ្យបានរួចរាល់យ៉ាងយូរត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣។

២. ប្រធាន អនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំ សង្កាត់នីមួយៗ ត្រូវពិគ្រោះពិភាក្សាដើម្បីបែងចែកសមាសភាពក្រុមការងារឱ្យចុះទទួលតាមភូមិនានាក្នុងឃុំ សង្កាត់ ស្នើមកប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ខណ្ឌសាមី ដើម្បីពិនិត្យ និងសម្រេចចាត់តាំងក្រុមការងារចុះតាមភូមិក្នុងឃុំ សង្កាត់នីមួយៗតាមការចាំបាច់ ឱ្យបានរួចរាល់យ៉ាងយូរត្រឹមដំណាច់ខែមករា ឆ្នាំ២០២៤។

៣. រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូន ឯកឧត្តម **វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ធ្វើជាសេនាធិការជូននាយករដ្ឋមន្ត្រីក្នុងការសម្របសម្រួលកិច្ចការរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ